អង្គការសហការគ្រប់ជ្រុងជ្រោយដើម្បីកម្ពុជា

# ឱកាសការងារ

## តួនាទី៖ មន្ត្រីផលិតសម្ភារៈ និងគ្រូបណ្តុះបណ្តាល – ការ៉ែត

អង្គការសហការគ្រប់ជ្រុងជ្រោយដើម្បីកម្ពុជា (អង្គការសហការ - ICC) គឺជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ដែលផ្តោតលើការអភិវឌ្ឍ និងពង្រឹងភាពអង់អាចដល់សហគមន៍ នៅប្រទេសកម្ពុជា។

**គម្រោងអប់រំផ្សារភ្ជាប់នឹងវប្បធម៌ដើម្បីភាពធន់នឹងអាកាសធាតុនៅក្នុងសហគមន៍ជនជាតិដើមភាគតិច** (CRE4CRI / KHK009, ២០២៦–២០២៩) នៅខេត្តរតនគិរី។ គម្រោងនេះមានគោលបំណងលើកកម្ពស់ការអប់រំពហុភាសាផ្អែកលើភាសាកំណើតប្រកបដោយបរិយាបន្ន (MT-MLE) សម្រាប់កុមារជនជាតិដើមភាគតិចរួមមាន ទំពួន គ្រឹង ព្រៅ ចារ៉ាយ និង ការ៉ែត នៅថ្នាក់មត្តេយ្យសិក្សា បឋមសិក្សា និងថ្នាក់អក្ខរកម្មផ្អែកលើសហគមន៍។

**គម្រោង៖** សូមប្រកាសជ្រើសរើសបេក្ខជនដែលមានសមត្ថភាព ដើម្បីធ្វើការជា **មន្ត្រីផលិតសម្ភារៈ និងគ្រូបណ្តុះបណ្តាលភាសាការ៉ែត**។

**ប្រាក់បៀវត្សរ៍៖** ចន្លោះពី ៣៨០ ទៅ ៤១០ ដុល្លារក្នុងមួយខែ បូករួមនឹងអត្ថប្រយោជន៍ផ្សេងៗទៀត។

## មន្ត្រីគម្រោង

| | | |
|---|---|---|
| មុខតំណែង | : | មន្ត្រីផលិតសម្ភារៈ និងគ្រូបណ្តុះបណ្តាលភាសាការ៉ែត |
| វិស័យការងារ | : | អប់រំពហុភាសាសម្រាប់ជនជាតិដើមភាគតិចនៅកម្ពុជា |
| ជំនាញរំពឹងទុក | : | មានសមត្ថភាពក្នុងការផលិតសម្ភារៈ ដោយមានភាពទាក់ទាញមានភាពច្នៃប្រឌិតហើយសមស្របតាមវប្បធម៌សហគមន៍ជនជាតិដើមភាគតិច ព្រមទាំងមានជំនាញក្នុងការបណ្តុះបណ្តាលគ្រូ ធ្វើការងារជាក្រុម និងកិច្ចសហការជាមួយភាគីពាក់ព័ន្ធ |
| មូលដ្ឋានទីតាំង | : | ខេត្តរតនគិរី |
| តំបន់ការងារគោលដៅ | : | ការិយាល័យ និងសហគមន៍គោលដៅជនជាតិដើមភាគតិច |
| កិច្ចសន្យាការងារ | : | មានថិរវេលាមិនកំណត់ |
| របាយការណ៍ឱ្យទៅ | : | អ្នកសម្របសម្រួលអប់រំបរិយាបន្ន |

## គោលបំណងការងារ

អ្នកកាន់មុខតំណែងនេះទទួលបន្ទុកបង្កើត កែសម្រួល និងធានាគុណភាពសម្ភារៈបង្រៀន និងរៀនជាភាសាការ៉ែត ព្រមទាំងកសាងសមត្ថភាពគ្រូបង្រៀនថ្នាក់មត្តេយ្យ បឋមសិក្សា និងអក្ខរកម្ម ឱ្យចេះប្រើប្រាស់សម្ភារៈទាំងនោះ។ មុខតំណែងនេះរួមចំណែកដោយផ្ទាល់ក្នុងការលើកកម្ពស់លទ្ធភាពទទួលបានការអប់រំ ការចូលរួម និងការរៀនសូត្រជាមូលដ្ឋានសម្រាប់កុមារជនជាតិដើមភាគតិច តាមរយៈការអប់រំពហុភាសាដោយផ្អែកលើភាសាកំណើត (MT-MLE) ដែលមានលក្ខណៈបរិយាបន្ន និងសមស្របនឹងវប្បធម៌។

## ទំនួលខុសត្រូវសំខាន់ៗ

- បង្កើត បកប្រែ និងធ្វើបច្ចុប្បន្នភាពសៀវភៅសិក្សា សម្រាប់ថ្នាក់មត្តេយ្យ/បឋមសិក្សា និង សម្រាប់ថ្នាក់អក្ខរកម្ម ដោយស្របតាមកម្មវិធីសិក្សារបស់ក្រសួងអប់រំយុវជន និងកីឡា។
- ធានាភាពត្រឹមត្រូវនៃអក្ខរាវិរុទ្ធភាសាកាវ៉េត សមស្របតាមវប្បធម៌ ព្រមទាំងអនុវត្តការរចនាបែបបរិយាបន្ន (រាប់បញ្ចូលកុមារពិការ និងយេនឌ័រ)។
- បញ្ចូលប្រធានបទស្តីពីភាពធន់នឹងអាកាសធាតុ ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ បរិស្ថាន និងសិទ្ធិកុមារ។
- ចងក្រងរឿងនិទាន ចម្រៀង និងចំណេះដឹងមូលដ្ឋានដោយសហការជាមួយចាស់ព្រឹទ្ធាចារ្យ/សហគមន៍ ព្រមទាំងសាកល្បងប្រើប្រាស់ក្នុងថ្នាក់រៀន និងប្រមូលមតិយោបល់ដើម្បីកែលម្អមុនពេលបោះពុម្ពផ្លូវការ។
- រៀបចំ និងផ្តល់ការបណ្តុះបណ្តាលដល់គ្រូបង្រៀនថ្នាក់មត្តេយ្យ បឋមសិក្សា និងអក្ខរកម្ម ព្រមទាំងតំរង់ទិសដល់មាតាបិតា គណៈកម្មការគ្រប់គ្រងសាលារៀន (SMCs) និងសហគមន៍។
- ចុះណែនាំ តាមដាន និងគាំទ្រគ្រូបង្រៀននៅក្នុងថ្នាក់រៀនជាប្រចាំ។
- ជួយគ្រូបង្រៀនក្នុងការស្វែងរក និងជួយសិស្សដែលមានការលំបាកក្នុងការរៀនសូត្រ តាមរយៈការបង្រៀនបំប៉ន និងការគាំទ្របន្ថែម។
- ទំនាក់ទំនងការងារជាមួយសាលារៀនគោលដៅ និងភាគីពាក់ព័ន្ធ(នាយកសាលា ការិយាល័យអប់រំស្រុក មន្ទីរអប់រំ)។
- ការចូលរួមកិច្ចប្រជុំបច្ចេកទេស ក្រុមការងារអប់រំពហុភាសា (MT-MLE) និងសិក្ខាសាលាបង្កើតសម្ភារៈសិក្សា។
- ប្រមូល និងដាក់ជូនទិន្នន័យសកម្មភាពត្រឹមត្រូវ តាមទម្រង់ដែលមន្ត្រីតាមដាន និងវាយតម្លៃតម្រូវ។
- រៀបចំផែនការ និងរបាយការណ៍សកម្មភាពប្រចាំខែ ត្រីមាស និងឆ្នាំ ព្រមទាំងករណីសិក្សា និងរឿងជោគជ័យ។
- រក្សាឯកសារមេ និងការគ្រប់គ្រងកំណែនៃសម្ភារៈភាសាកាវ៉េតទាំងអស់។
- គ្រប់គ្រងថវិកា ប្រាក់បុរេប្រទាន និងទ្រព្យសម្បត្តិគម្រោងប្រកបដោយការទទួលខុសត្រូវ។
- បំពេញភារកិច្ចពាក់ព័ន្ធផ្សេងទៀត តាមការចាត់តាំងរបស់ប្រធានផ្ទាល់។

## លក្ខខណ្ឌតម្រូវ ឬលក្ខណៈសម្បត្តិ

☑ មានបរិញ្ញាបត្រផ្នែកអប់រំ អក្សរសាស្រ្តខ្មែរ វិទ្យាសាស្រ្តសង្គម ឬជំនាញពាក់ព័ន្ធ (ឬមានសញ្ញាបត្រ/វិញ្ញាបនបត្រគរុកោសល្យ ឬបទពិសោធន៍ពាក់ព័ន្ធនានាត្រូវបានពិចារណា។

☑ ចាំបាច់ត្រូវចេះនិយាយ អាន និងសរសេរភាសាកាវ៉េត។

☑ មានសមត្ថភាពល្អក្នុងការប្រើប្រាស់ភាសាខ្មែរ (និយាយ និងសរសេរ) បើចេះភាសាអង់គ្លេសកាន់តែប្រសើរ។

☑ មានបទពិសោធន៍យ៉ាងហោចណាស់ ០៣ ឆ្នាំ លើកម្មវិធីអប់រំជាភាសា។

☑ មានបទពិសោធន៍ច្បាស់លាស់ក្នុងការបង្កើត បកប្រែ ឬកែសម្រួលសម្ភារៈសិក្សាសម្រាប់សិស្សថ្នាក់មត្តេយ្យ បឋមសិក្សា ឬអក្ខរកម្មមនុស្សពេញវ័យ។

☑ មានបទពិសោធន៍សម្របសម្រួលការរៀនសម្រាប់មនុស្សពេញវ័យ ការបណ្តុះបណ្តាលគ្រូក្នុងពេលបំពេញការងារ និងការណែនាំនៅក្នុងថ្នាក់រៀន។

☑ បទពិសោធន៍ធ្វើការជាមួយសហគមន៍ជនជាតិដើមភាគតិច។

☑ យល់ដឹងអំពីការអប់រំបរិយាបន្ន បរិយាបន្នជនមានពិការភាព សមភាពយេនឌ័រ និងកិច្ចការពារសុវត្ថិភាពកុមារ។

☑ យល់ដឹងអំពីការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងបញ្ហាបរិស្ថាន។

☑ មានចំណេះដឹងកុំព្យូទ័រល្អ (Microsoft Word, Excel, PowerPoint, Publisher អ៊ីមែល និងអ៊ីនធឺណិត) អាចប្រើពុម្ពអក្សរយូនីកូដខ្មែរ និងកាវ៉េត។

☑ មានជំនាញសម្របសម្រួល និងទំនាក់ទំនង។
☑ ប្តេជ្ញាចិត្តគោរពចំពោះសិទ្ធិ វប្បធម៌របស់ជនជាតិដើមភាគតិច និងគុណតម្លៃរបស់អង្គការ។
☑ មានលទ្ធភាព និងឆន្ទៈធ្វើដំណើរជាញឹកញាប់ទៅភូមិ និងសាលារៀនគោលដៅដាច់ស្រយាល និងស្នាក់នៅមូលដ្ឋានពេលយប់។
☑ មានឆន្ទៈគោរពតាមគោលនយោបាយថែរក្សាសុវត្ថិភាពកុមារ និងក្រមសីលធម៌របស់អង្គការ ព្រមទាំងទទួលការត្រួតពិនិត្យប្រវត្តិរូបតាមតម្រូវការ។
☑ ស្មោះត្រង់ គួរឱ្យទុកចិត្ត មានការជម្រុញខ្លួនឯង អាចធ្វើការដោយឯករាជ្យ។

## សមភាព និងការការពារកុមារ

អង្គការយើងផ្តល់ឱកាសការងារស្មើភាពគ្នា និងលើកទឹកចិត្តយ៉ាងខ្លាំងដល់បេក្ខជនស្ត្រី បេក្ខជនជនជាតិដើមភាគតិច និងបេក្ខជនជនពិការ ឱ្យដាក់ពាក្យ។ បេក្ខជនដែលនិយាយភាសាកាវ៉ែតជាភាសាកំណើតត្រូវបានផ្តល់អាទិភាព។ អង្គការប្រកាន់ខ្ជាប់នូវគោលនយោបាយការពារ និងថែរក្សាសុវត្ថិភាពកុមារ។ បេក្ខជនដែលត្រូវបានជ្រើសរើសត្រូវឆ្លងកាត់ការត្រួតពិនិត្យប្រវត្តិរូប និងចុះហត្ថលេខាលើក្រមសីលធម៌របស់អង្គការ។

## របៀបដាក់ពាក្យ

បេក្ខជនដែលមានចំណាប់អារម្មណ៍ សូមដាក់ជូនឯកសារដូចខាងក្រោម៖

- លិខិតដាក់ពាក្យសុំបម្រើការងារ (Cover Letter)
- ប្រវត្តិរូបសង្ខេប (CV) ដែលមានឈ្មោះអ្នកធានាចំនួន ០២រូប
- ច្បាប់ចម្លងសញ្ញាបត្រ វិញ្ញាបនបត្រ អត្តសញ្ញាណប័ណ្ណ បើមានប័ណ្ណបើកបរកាន់តែប្រសើរ

ទម្រង់នៃពាក្យស្នើសុំអាចទាញយកពីគេហទំព័ររបស់អង្គការសហការ៖ https://icc.org.kh/opportunities.php
ហើយបេក្ខជនត្រូវផ្ញើឯកសារទន់ (soft copy) ដោយបំលែងជា PDF ទៅកាន់អ៊ីម៉ែលប្រធានគម្រោង៖
rtk.pm@icc.org.kh និងចម្លង ( CC )៖ mle.pc@icc.org.kh, rtk.meal@icc.org.kh ។

**បញ្ជាក់៖** មានតែបេក្ខជនដែលជាប់ក្នុងបញ្ជីសម្រាំងប៉ុណ្ណោះ នឹងធ្វើការទាក់ទងតាមទូរសព្ទ ដើម្បីធ្វើការណាត់ សម្ភាសន៍។ អង្គការសហការ (ICC) មានការប្តេជ្ញាក្នុងការការពារកុមារ និង ក្នុងការការពារពីការកេងប្រវ័ញ្ច ការរំលោភបំពាន និងការបៀតបៀនផ្លូវភេទ។ ម្លោះហើយ ការផ្តល់ការងារ គឺតម្រូវឱ្យមានការត្រួតពិនិត្យពីប្រវត្តិរូបរបស់បេក្ខជន និង កំណត់ត្រាផ្សេងៗរបស់បេក្ខជន ដែលធ្លាប់ស្នាក់នៅ ឬបម្រើការងារ។

**<u>កាលបរិច្ឆេទឈប់ទទួលពាក្យ៖</u> ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៦ វេលាម៉ោង៥:០០ល្ងាច**

**<u>ព័ត៌មានទំនាក់ទំនង៖</u>**

ការិយាល័យអង្គការសហការ (ICC) ស្ថិតនៅភូមិអូរកន្សែង សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី។
លេខទំនាក់ទំនង៖ 097 72 23 886 / 097 21 61 530